ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៧៣៥ សហវ.គយ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការគ្រប់គ្រងទំនិញកំណត់ពិសេស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពី ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញដាប់កម្រិតកំណត់
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ទំនិញកំណត់ពិសេស គឺជាប្រភេទទំនិញដែលមានវេទយិតភាព ឬទំនិញដែលជាប់ពន្ធខ្ពស់ស្របតាមបញ្ញត្តិកថាខណ្ឌទី ២ មាត្រា ៨ នៃច្បាប់ស្តីពីគយ ។ ទំនិញកំណត់ពិសេសជាកម្មវត្ថុនៃការកំណត់បន្ថែមនូវនីតិវិធីនៃការត្រួតពិនិត្យ និងការដាក់កម្រិតកំណត់លើការដឹកជញ្ជូន ការធ្វើចរាចរ ការធ្វើសន្និធិ និងការកាន់រក្សាទំនិញទាំងនេះ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ប្រការ ២.-**

ទំនិញជាប់ពន្ធខ្ពស់ គឺជាប្រភេទទំនិញដែលត្រូវជាប់កាតព្វកិច្ចពន្ធ និងអាករនាំចូលតាមអត្រាគរពូន (Compound Rate) លើសពី ២៧ ( ម្ភៃប្រាំពីរ ) ភាគរយ ។

**ប្រការ ៣.-**

ទំនិញមានវេទយិតភាព គឺជាប្រភេទទំនិញដែល :

- ស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ស្របតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- មានសក្តានុពលពាក់ព័ន្ធនឹងចំណូលពន្ធ អាករនាំចូល និងអំពើរត់គេចពន្ធដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៤.-**

សម្រាប់មុខទំនិញដែលជាទំនិញកំណត់ពិសេស ដូចមានចែងក្នុងប្រការ ១ ប្រការ ២ និងប្រការ ៣ នៃប្រកាសនេះ សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ត្រូវគ្របដណ្តប់នៅទូទាំងដែនគយ រាប់បញ្ចូលទាំងក្នុងវង់អំណាចគយផងដែរ ។

ចំពោះមុខទំនិញផ្សេងទៀតដែលពុំមែនជាទំនិញកំណត់ពិសេស សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ត្រូវគ្របដណ្តប់តែក្នុងវង់អំណាចគយប៉ុណ្ណោះ ។

ក្នុងករណីមានការដេញប្រដាប់ចាប់ប្រកីងពីក្នុងវង់អំណាចគយឬការរកឃើញដោយចៃដន្យនូវទំនិញដែលមិនស៊ីគ្នានឹងការប្រកាស ឬឯកសារដែលមានជាប់នឹងអ្នកកាន់កាប់ សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ អាចគ្របដណ្តប់នៅទូទាំងដែនគយ ទោះបីទំនិញនេះពុំមែនជាប្រភេទទំនិញកំណត់ពិសេសក្តី ។

**ប្រការ ៥.-**

ក្នុងករណីចាំបាច់ នាយកទីចាត់ការគយ និងរដ្ឋាករ អាចស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការកែសម្រួល ឬបំពេញបន្ថែមមុខទំនិញនៅក្នុងបញ្ជីទំនិញកំណត់ពិសេស ។

**ប្រការ ៦.-**

យោងទៅតាមកាលៈទេសៈជាក់ស្តែង និងដើម្បីធានាប្រសិទ្ធភាពការងារគយនិងរដ្ឋាករ នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ និងកែសម្រួលពីពេលមួយទៅ

ពេលមួយនូវនីតិវិធីគយពាក់ព័ន្ធនឹងការដឹកជញ្ជូន ការចែកចាយ ការធ្វើសន្និធិ និងការកាន់រក្សាទំនិញកំណត់ពិសេស រួមទាំងលទ្ធភាពនៃ ការតម្រូវឱ្យបិទលតាប័ត្រ ឬត្រាគយ ការតម្រូវឱ្យដឹកជញ្ជូនដោយមធ្យោបាយមានការអនុញ្ញាត ការតម្រូវឱ្យគ្រប់គ្រងចុះបញ្ជីដោយឡែក និងការតម្រូវឱ្យដាក់ឯកសារគតិយុត្តិពាក់ព័ន្ធអមភ្ជាប់នឹងទំនិញនេះជាដើម ។

**ប្រការ ៧.-**

អ្នកនាំចេញ អ្នកនាំចូល ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញកំណត់ពិសេស មានការកិច្ចអនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់របស់នាយកដ្ឋានទីចាត់ការគយ និងរដ្ឋាករ ពាក់ព័ន្ធនឹងនីតិវិធីនៃការដឹកជញ្ជូន ការធ្វើចរាចរ ការធ្វើសន្និធិ ការកាន់រក្សា និងការតម្រូវផ្សេងទៀតពាក់ព័ន្ធនឹងទំនិញកំណត់ពិសេស ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន ៖</u>**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៩
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ